- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ។

ត្រាស់បង្គាប់

មាត្រា ១ .- ត្រូវបានតែងតាំង ឯកឧត្តម សួន ជីវគុណ ជាសមាជិកក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ មានឋានៈស្មើអនុរដ្ឋលេខាធិការ ។

មាត្រា ២ .- ត្រូវបានប្រគល់ភារកិច្ចជូន ឯកឧត្តម សុខ ឡេង អោយបំពេញមុខងារជាអគ្គនាយកនៃអគ្គនាយកដ្ឋានធនធានរ៉ែ របស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

មាត្រា ៣ .- បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៤ .- សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៥ .- ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ ៣៦២ ច.ល
ដើម្បីចម្លងចែកផ្សាយ
រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ ៨ ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
ឈាង ផាន

៣៧៧-០៥០៥.៣៩៥

ធ្វើនៅព្រះបរមរាជវាំង.រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០០៥

ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៣៦៥

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរជនា សម្ពោហាគារ កម្ពុជឯករាជ្យបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃ ព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា .

-បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី .

-បានទ្រង់យល់ព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា .

-បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : បំពាក់គ្រឿងឥស្សរិយយស **សហមេត្រី** តាមលំដាប់ថ្នាក់ ជូនកងឯកភាព ចំនួន០៤ និងនាយទាហានជាន់ខ្ពស់ ចំនួន ២៥រូប នៃកងទ័ពប្រជាជនវៀតណាម ដែលមានស្នាដៃល្អក្នុងការធ្វើសហប្រតិបត្តិការ ជួយឧបត្ថម្ភគាំទ្រ ដល់កងយោធពលខេមរភូមិន្ទ ដូចមានរាយនាមខាងក្រោម :-

ក-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេរីវឌ្ឍន៍ :

-ឧត្តមសេនីយ៍កងទ័ព **ផាម វ៉ាន់ចា** (Pham Van Tra) រដ្ឋមន្ត្រីក្រសួងការពារជាតិ កងទ័ពប្រជាជនវៀតណាម

ខ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ មហាសេនា :

១-ឧត្តមសេនីយ៍ឯក **ដូ ទ្រុងយឿង** (Do Trung Duong) នាយករងអគ្គសេនាធិការ កងទ័ពប្រជាជនវៀតណាម

២-ឧត្តមសេនីយ៍ឯក **ផាម វ៉ាន់ឡុង** (Pham Van Long) អគ្គនាយករង រងអគ្គនាយកដ្ឋាននយោបាយ កងទ័ពប្រជាជនវៀតណាម

គ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ ធិបឌិន្ទ :

• ចំពោះកងឯកភាព :

-ស្នងការសាលា អគ្គសេនាធិការ កងទ័ពប្រជាជនវៀតណាម

• ចំពោះនាយឧត្តមសេនីយ៍ :

១-ឧត្តមសេនីយ៍ទោ **ផាម ថាញ់ឡឹន** (Pham Thanh Lan) នាយក នាយកដ្ឋានទាក់ទងអន្តរជាតិ កងទ័ពប្រជាជនវៀតណាម

២-ឧត្តមសេនីយ៍ទោ **ដាំង វ៉ាន់កឹន** (Dang Van Can) នាយកខុទ្ទកាល័យ ក្រសួងការពារជាតិ កងទ័ពប្រជាជនវៀតណាម

៣-ឧត្តមសេនីយ៍ទោ **ង៉ូ អានហ៊យ** (Ngo An Hoi) នាយកខុទ្ទកាល័យ អគ្គសេនាធិការ កងទ័ពប្រជាជនវៀតណាម

៤-ឧត្តមសេនីយ៍ទោ **ង្វៀន ចុងថាំង** (Nguyen Trong Thang) នាយក នាយកដ្ឋានសាលា កងទ័ពប្រជាជនវៀតណាម

៥-ឧត្តមសេនីយ៍ទោ **ង្វៀន វ៉ាន់ហ័ងដាវ** (Nguyen Van Hoang Dao) នាយកមន្ទីរពេទ្យ ១៧៥ កងទ័ពប្រជាជនវៀតណាម

ឃ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ សេនា :

• ចំពោះកងឯកភាព :

១-វិទ្យាស្ថានការពារជាតិ កងទ័ពប្រជាជនវៀតណាម

២-វិទ្យាស្ថាននយោបាយយោធា កងទ័ពប្រជាជនវៀតណាម

៣-វិទ្យាស្ថានកងទ័ពជើងគោក កងទ័ពប្រជាជនវៀតណាម

• ចំពោះនាយឧត្តមសេនីយ៍ :

១-ឧត្តមសេនីយ៍ទោ **ឌិញ វ៉ាន់បុង** (Dinh Van Bong) នាយកវិទ្យាស្ថានការពារអាកាស កងទ័ពប្រជាជនវៀតណាម

២-ឧត្តមនាវីត្រី **ផាម ហុងធន់** (Pham Hong Thuan) នាយកវិទ្យាស្ថានជើងទឹក កងទ័ពប្រជាជនវៀតណាម

៣-ឧត្តមសេនីយ៍ទោ **ផាម ហ្សាខាញ់** (Pham Gia Khanh) នាយកវិទ្យាស្ថានពេទ្យយោធា កងទ័ពប្រជាជនវៀតណាម

៤-ឧត្តមសេនីយ៍ទោ **ង្វៀន ឌឹកល្វៀន** (Nguyen Duc Luyen) នាយក វិទ្យាស្ថានបច្ចេកទេសយោធា កងទ័ពប្រជាជនវៀតណាម

៥-ឧត្តមសេនីយ៍ទោ **ដុង មិញតាយ** (Dong Minh Tai) នាយកវិទ្យាស្ថានភស្តុភារកងទ័ពប្រជាជនវៀតណាម

៦-វរសេនីយ៍ឯកពិសេស **ចិន ស៊ន់ទិញ** (Tran Xuan Tinh) នាយកវិទ្យាស្ថានការពារព្រំដែន កងទ័ពប្រជាជនវៀតណាម

៧-វរសេនីយ៍ឯកពិសេស **វូ ធៀតគឿង** (Vu Thiet Cuong) នាយកវិទ្យាស្ថាន វិទ្យាសាស្ត្រយោធា អគ្គនាយកដ្ឋានទី២ កងទ័ពប្រជាជនវៀតណាម

ខ-គ្រឿងឥស្សរិយយស សហមេត្រី ថ្នាក់ អស្សឫទ្ធិ :

១-វរសេនីយ៍ឯកពិសេស **ផាំ វៀតថាយ** (Pham Viet Thai) នាយករង សាលានាយទាហាន កងទ័ពជើងគោកទី២ កងទ័ពប្រជាជនវៀតណាម

២-វរសេនីយ៍ឯកពិសេស **ហ្សាប វ៉ាន់ធៀន** (Giap Van Thien) នាយកសាលានាយទាហាន ទ័ពពិសេស (ដាក់កុង) កងទ័ពប្រជាជនវៀតណាម

៣-វរសេនីយ៍ឯកពិសេស **ង្វៀន វៀតហ៊ុង** (Nguyen Viet Hung) នាយកសាលានាយទាហាន រថក្រោះ-រថពាសដែក កងទ័ពប្រជាជនវៀតណាម

៤-វរសេនីយ៍ឯកពិសេស **ផាម ក្វាងស៊ន់** (Pham Quang Xuan) នាយកសាលានាយទាហាន ទ័ពជាង កងទ័ពប្រជាជនវៀតណាម

៥-វរសេនីយ៍ឯកពិសេស **ចាន ក្វៀតទៀន** (Tran Quyet Tien) នាយកសាលានាយទាហាន កាំភ្លើងធំ កងទ័ពប្រជាជនវៀតណាម

៦-វរសេនីយ៍ឯកពិសេស **ជូ ឌុយថាវ** (Chu Duy Thao) នាយកសាលានាយទាហាន គីមីសាស្ត្រយោធា កងទ័ពប្រជាជនវៀតណាម

៧-វរសេនីយ៍ឯកពិសេស **ង្វៀន ស៊ន់ដាយ** (Nguyen Xuan Dai) នាយករង ទទួលការងារនយោបាយ សាលានាយទាហានវិទ្យុទាក់ទង កងទ័ពប្រជាជនវៀតណាម

៨-វរសេនីយ៍ឯកពិសេស **ង្វៀន អានធ្វៀន** (Nguyen An Thuyen) នាយកសាលាមធ្យមជាន់ខ្ពស់ វប្បធម៌ សិល្បៈ កងទ័ព ប្រជាជនវៀតណាម

៩-វរសេនីយ៍ឯកពិសេស **ប៊ុយ ក្វាងឡាយ** (Bui Quang Lai) នាយករង ទទួលនយោបាយសាលាមធ្យមជាន់ខ្ពស់ Vin-hem pic អគ្គនាយកដ្ឋានបច្ចេកទេស កងទ័ពប្រជាជនវៀតណាម

១០-វរសេនីយ៍ឯកពិសេស **ឡេ ម៉ាញ់ហ៊ុង** (Le Manh Hung) នាយកសាលាមធ្យមសិក្សាព្រំដែន បញ្ជាការដ្ឋាន កងទ័ពការពារព្រំដែន កងទ័ពប្រជាជនវៀតណាម

មាត្រា២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអោយបានសំរេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

៣ការ-០៥០៨-៣៤៦

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ,ថ្ងៃទី ៥ ខែ សីហា ឆ្នាំ ២០០៥

117

លេខ ...ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ,ថ្ងៃទី ១៦ ខែសីហា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល

ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៣៦៦

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សម្ពោហាគាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/ នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានទ្រង់យល់ព្រះរាជក្រមលេខ ០៦ / នស / ៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា១ : តែងតាំង ឯកឧត្តម **ឈន ហៃ** ជាឯកអគ្គរាជទូតវិសាមញ្ញ និង ពេញសមត្ថភាព នៃព្រះរាជាណាចក្រកម្ពុជា ប្រចាំសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ ជំនួសឯកឧត្តម **អ៊ី ម៉ាន់រ៉ែន** ដែលត្រូវបានទទួលការតែងតាំងក្នុងមុខតំណែងថ្មី ។

មាត្រា២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា៣ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តអោយបានសំរេច នូវព្រះរាជក្រឹត្យនេះ ។

មាត្រា៤ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះ តទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ
នរោត្តម សីហមុនី

លេខ ...១៩ ច.ល
ដើម្បីចម្លងចែក
រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ សីហា ឆ្នាំ២០០៥
អគ្គលេខាធិការរាជរដ្ឋាភិបាល
[signature]
សៅ ឌី តាន់

៣៤៤-០៥០៨.៣៥៧

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៤ ខែ សីហា ឆ្នាំ ២០០៥

ព្រះរាជក្រឹត្យ

នស/រកត/០៨០៥/៣៦៤

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សម្ពោហាភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យ លេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា

ត្រាស់បង្គាប់

មាត្រា ១ : ត្រូវបានប្រគល់ភារកិច្ចជូនឯកឧត្តម ឆេស សុខម៉េង ឱ្យបំពេញមុខងារជា អគ្គលេខាធិការរង រាជរដ្ឋាភិបាល មានឋានៈស្មើ អនុរដ្ឋលេខាធិការ ។

មាត្រា ២ : សម្តេចនាយករដ្ឋមន្ត្រី នៃរាជរដ្ឋាភិបាលកម្ពុជា ត្រូវអនុវត្តឱ្យបានសម្រេចនូវព្រះរាជក្រឹត្យនេះ ។

មាត្រា ៣ : ព្រះរាជក្រឹត្យនេះ ចូលជាធរមាន ចាប់ពីថ្ងៃឡាយព្រះហស្តលេខានេះតទៅ ។

ព្រះហស្តលេខា និងព្រះរាជលញ្ឆករ

នរោត្តម សីហមុនី

៣១ល-០៥០៨-៣៨៩

ធ្វើនៅព្រះបរមរាជវាំង រាជធានីភ្នំពេញ ថ្ងៃទី ៩ ខែ សីហា ឆ្នាំ ២០០៥

លេខ ៣២៤ ច.ល

ដើម្បីចម្លងចេញ

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ ៨/៧ ឆ្នាំ២០០៥

អគ្គលេខាធិការរាជរដ្ឋាភិបាល

[illegible] តាន់

42

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ៧៦៤ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

៖៙៖

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ០១គ្រឿង ជូនអង្គការ JHP ដែលបានឧបត្ថម្ភថវិកាចំនួន ២០.៦៧០ ដុល្លារ សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៣បន្ទប់ ធ្វើពីបេតុងប្រក់ក្បឿង នៅសាលា បឋមសិក្សាក្តីតាកុយ ក្នុងឃុំវាលស្បូវ ស្រុកកៀនស្វាយ ខេត្តកណ្តាល ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ សីហា ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SR.99

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៦៥. អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៙៙

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ០១គ្រឿង ជូនអង្គការ ***លូធើរ៉ាន បំរើពិភពលោក*** (LWF) ដែលបានឧបត្ថម្ភថវិកា ចំនួន ៣១.៣១៥.២៨ ដុល្លារអាមេរិក សំរាប់ជួយសាងសង់អគារសិក្សា ចំនួន០២ខ្នង មាន០៦បន្ទប់ គឺនៅសាលាបឋមសិក្សា រំចេក ក្នុងឃុំយាអង្គ ចំនួន០១ខ្នង និងនៅសាលាបឋមសិក្សា តាំងហោង ក្នុងឃុំអមលាំង ចំនួន០១ខ្នង ក្នុងស្រុកថ្ពង ខេត្តកំពង់ស្ពឺ ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្ត អនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

SR.101

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៦៨ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

៚

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

សម្រេច

មាត្រា១ៈ ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ជូនលោក OHTSUKA MASAAKI ដែលបានឧបត្ថម្ភថវិកា តាមរយៈអង្គការ JHP នូវទឹកប្រាក់ចំនួន ២៧.៣៧០ ដុល្លារអាមេរិក សំរាប់ជួយសាងសង់អគារសិក្សា ០១ខ្នង មាន០៥បន្ទប់ បង្គន់អនាម័យ ០១ខ្នង មាន០៣បន្ទប់ អណ្តូងទឹក ០១ ព្រមទាំងបំពាក់សម្ភារឹមគ្រប់ប្រភេទ នៅសាលាបឋមសិក្សាត្នោតពុក ស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ ។

មាត្រា២ៈ រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្ត អនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ៨ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា ១ និង មាត្រា ២
- រាជកិច្ច
SR.95 - ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ:...៦៦៥...អ.ន.ក្រ.បក

អនុក្រឹត្យ
ស្តីពី
ការតែងតាំងក្រុមប្រឹក្សាភិបាល ប្រចាំសាកលវិទ្យាល័យភូមិន្ទកសិកម្ម

* * ***

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៤/១៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៥ ស្តីពីការកែសំរួលខ្លឹមសារមាត្រា ៥ ជំពូកទី ២ ផ្នែកទី ១ នៃអនុក្រឹត្យលេខ ១១៥ អនក្រ.បក ចុះថ្ងៃទី ២៧ ខែ ធ្នូ ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ស ម្រេ ច

មាត្រា ១ : ត្រូវបានតែងតាំងក្រុមប្រឹក្សាភិបាលប្រចាំសាកលវិទ្យាល័យភូមិន្ទកសិកម្ម អាណត្តិទី ២ ដែលមានសមាសភាពដូចខាងក្រោម :

១-លោក **ម៉ក់ គីមហុង**	តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ	ជាប្រធាន
២-លោក **ស៊ុម សាន**	តំណាងទីស្តីការគណៈរដ្ឋមន្ត្រី	ជាសមាជិក
៣-លោក **រស់ ចរេច**	តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	ជាសមាជិក
៤-លោក **រ៉ត្ន សុខា**	តំណាងក្រសួងអប់រំយុវជននិងកីឡា	ជាសមាជិក
៥-លោក **ភុច សាវ៉ាត**	តំណាងក្រសួងបរិស្ថាន	ជាសមាជិក
៦-លោក **សៅ ជីវ័ន្ត**	តំណាងក្រសួងអភិវឌ្ឍន៍ជនបទ	ជាសមាជិក
៧-ឯកឧត្តម **ចាន់ ណារ៉េត**	សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម	ជាសមាជិកស្វ័យប្រវត្តិ
៨-លោក **ឌី ចាន់ណា**	តំណាងក្រុមប្រឹក្សាស្រាវជ្រាវកសិកម្ម	ជាសមាជិក
៩-លោកស្រី **សុខ សុន្ធាវី**	តំណាងសភាពាណិជ្ជកម្ម	ជាសមាជិក

១០-លោក **សរ សុវណ្ណ** តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ជាសមាជិក

១១-លោក **ជូខ សុផល** តំណាងបុគ្គលិកសាកលវិទ្យាល័យភូមិន្ទកសិកម្ម ជាសមាជិកស្ម័យប្រវត្តិ

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខា - ប្រមាញ់ និងនេសាទ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួន មានភារកិច្ចអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ ៧ ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ខុទ្ទកាល័យសម្តេច-ឯកឧត្តមឧបនាយករដ្ឋមន្ត្រី
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ដូចមាត្រា ៣
-ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ ៖ ៦៧០ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការផ្តល់មេដាយសហមេត្រី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៧០៤/១២៤ចុះថ្ងៃទី១៥ ខែកក្កដាឆ្នាំ២០០៤ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាស អោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយសហមេត្រីថ្នាក់ធិបឌិន្ទ** ជូនលោក **ឡាកូស ដានីញ៉ែល (LACOSTE Daniel)** មន្ត្រីប៉ូលីសជាតិបារាំង ប្រចាំស្ថានទូតសាធារណៈរដ្ឋបារាំង នៅព្រះរាជាណាចក្រកម្ពុជា ដែលបានសហការល្អប្រសើរជាមួយ អគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ ក្នុងការបង្ក្រាបបទល្មើសឆ្លងដែន។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចក្នុងមាត្រា១ និងមាត្រា២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ៦៧២ . អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

※ ※ ※ ※ ※ ※

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខនស/រកត / ០៧០៤ / ១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

ស ម្រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ជូនដល់នាយនគរបាលជាន់ខ្ពស់ នាយនគរបាល និងនាយនគរបាលរង ចំនួន ៨៤ រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ ដូចមានរាយនាមខាងក្រោម :

ក.<u>មេដាយមាសការងារ</u>

១	-	លោកឧត្តមសេនីយ៍ឯក	**មាំ**	**ឈឿន**	ប្រធាននាយកដ្ឋានបណ្តុះបណ្តាល និងវិក្រឹត្យការ
២	-	លោកឧត្តមសេនីយ៍ទោ	**ម៉េង**	**សុផាន់ណា**	ប្រធានសេនាធិការដ្ឋាន
៣	-	លោកឧត្តមសេនីយ៍ទោ	**សុខ**	**សួស្តី**	អនុប្រធានទី១ នៃនាយកដ្ឋានកណ្តាលនគរបាលព្រំដែន
៤	-	លោកឧត្តមសេនីយ៍ត្រី	**សួរ**	**តាំងឆាយ**	អនុប្រធាននាយកដ្ឋានកណ្តាលនគរបាលព្រំដែន
៥	-	លោកវរៈសេនីយ៍ឯក	**ឈុំ**	**សាយ**	អនុប្រធានសេនាធិការដ្ឋាន
៦	-	លោកវរៈសេនីយ៍ឯក	**ឌុត**	**ម៉ៅ**	អនុប្រធានសេនាធិការដ្ឋាន
៧	-	លោកវរៈសេនីយ៍ឯក	**ផាន់**	**សុផល**	អនុប្រធានសេនាធិការដ្ឋាន
៨	-	លោកវរៈសេនីយ៍ឯក	**សម**	**វណ្ណវីរៈ**	អនុប្រធានសេនាធិការដ្ឋាន
៩	-	លោកវរៈសេនីយ៍ឯក	**គី**	**ដារ៉ា**	អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និង អាស៊ាន
១០	-	លោកវរៈសេនីយ៍ឯក	**ចាន់**	**សុផល**	អនុប្រធាននាយកដ្ឋានបច្ចេកទេសព្រំដែន

១១ -	លោកវរៈសេនីយ៍ឯក	ប៉ាង	ឆេង	អនុប្រធាននាយកដ្ឋាននគរបាលបច្ចេកទេសវិទ្យាសាស្ត្រ
១២ -	លោកវរៈសេនីយ៍ឯក	អាត់	ខែម	ស្នងការនគរបាលខេត្តបន្ទាយមានជ័យ
១៣ -	លោកវរៈសេនីយ៍ឯក	ប្រាជ្ញ	រីម	ស្នងការនគរបាលខេត្តឧត្តរមានជ័យ
១៤ -	លោកស្រីវរៈសេនីយ៍ទោ	ធូ	ប៊ុនរិទ្ធ	នាយការិយាល័យ នៃសេនាធិការដ្ឋាន
១៥ -	លោកវរៈសេនីយ៍ទោ	មុិញ	សុធីវណ្ណ	នាយការិយាល័យ នៃសេនាធិការដ្ឋាន
១៦ -	លោកវរៈសេនីយ៍ទោ	ទាង	សុយាង	នាយការិយាល័យ នៃសេនាធិការដ្ឋាន
១៧	លោកវរៈសេនីយ៍ទោ	ហាវ	ចាន់សិទ្ធី	នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
១៨	លោកវរៈសេនីយ៍ទោ	វ៉ាន់	សារិទ្ធ	នាយការិយាល័យ នៃនាយកដ្ឋានបុគ្គលិក
១៩ -	លោកវរៈសេនីយ៍ទោ	គីម	សុខុន	ស្នងការរងទី១ នៃស្នងការដ្ឋាននគរបាលខេត្តពោធិសាត់
២០ -	លោកវរៈសេនីយ៍ទោ	ស	ថេង	នាយការិយាល័យ នៃនាយកដ្ឋាននគរបាលសេដ្ឋកិច្ច
២១ -	លោកវរៈសេនីយ៍ទោ	សុខ	វាសនា	ស្នងការរងនគរបាលខេត្តឧត្តរមានជ័យ
២២ -	លោកវរៈសេនីយ៍ទោ	មុន្នី	រតនា	មន្ត្រី នៃសេនាធិការដ្ឋាន
២៣ -	លោកវរៈសេនីយ៍ត្រី	អេង	សាខន	នាយរងការិយាល័យ នៃនាយកដ្ឋាននគរបាលសេដ្ឋកិច្ច
២៤ -	លោកវរៈសេនីយ៍ត្រី	ហាយ	ប៊ុនធឿន	អនុប្រធានលេខាធិការនាយកដ្ឋានកណ្តាលនគរបាលព្រំដែន
២៥ -	លោកវរៈសេនីយ៍ត្រី	យ៉ន	សោភ័ណ	នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង
២៦ -	លោកវរៈសេនីយ៍ត្រី	កឹង	ឃន	មេបញ្ជាការវរសេនាតូចនៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង
២៧ -	លោកវរៈសេនីយ៍ត្រី	ចាន់	ស៊ីថា	មេបញ្ជាការវរសេនាតូចនៃស្នងការដ្ឋាននគរបាលខេត្តស្វាយរៀង
២៨ -	លោកវរៈសេនីយ៍ត្រី	ព្រំ	សារុន	នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តពោធិសាត់
២៩ -	លោកវរៈសេនីយ៍ត្រី	រៀម	សរ	នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ,
៣០ -	លោកវរៈសេនីយ៍ត្រី	ប៊ុល	វុទ្ធី	នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តឧត្តរមានជ័យ
៣១ -	លោកវរៈសេនីយ៍ត្រី	វង្ស	វិត	នាយការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តបន្ទាយមានជ័យ
៣២ -	លោកអនុសេនីយ៍ឯក	ញ៉ែម	ណារ័ត្ន	នាយរងការិយាល័យ នៃស្នងការដ្ឋាននគរបាលខេត្តពោធិសាត់
៣៣	លោកអនុសេនីយ៍ឯក	គង់	ភិរុណ	មន្ត្រី នៃសេនាធិការដ្ឋាន
៣៤ -	កញ្ញាអនុសេនីយ៍ឯក	សៅ	ពិសី	មន្ត្រី នៃសេនាធិការដ្ឋាន

ខ.<u>មេដាយឃ្លាំងការខារ</u>

១ -	លោកវរៈសេនីយ៍ត្រី	កៅ	យ៉ាត	មេបញ្ជាការរង នៃសេនាធិការដ្ឋាន
២ -	លោកវរៈសេនីយ៍ត្រី	ខ្វាន់	ប៊ុនធឿន	មេបញ្ជាការរង នៃសេនាធិការដ្ឋាន
៣	លោកវរៈសេនីយ៍ត្រី	ម៉ាំង	គា	មេបញ្ជាការរង នៃសេនាធិការដ្ឋាន
៤ -	លោកវរៈសេនីយ៍ត្រី	តុប	ចាន់ផន	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
៥ -	លោកវរៈសេនីយ៍ត្រី	ឡៀប	វណ្ណរិទ្ធ	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន

៦	-	លោកវរៈសេនីយ៍ត្រី	វ៉ា	សាម៉ុអ៊ី	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
៧	-	លោកវរៈសេនីយ៍ត្រី	ជេត	វណ្ណា	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
៨	-	លោកវរៈសេនីយ៍ត្រី	ហេង	សុត្ថា	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
៩	-	លោកវរៈសេនីយ៍ត្រី	សិទ្ធ	ប៊ុនធី	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
១០	-	លោកវរៈសេនីយ៍ត្រី	អ៊ុម	វិសាន	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
១១	-	លោកវរៈសេនីយ៍ត្រី	ហួរ	សាអ៊ី	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
១២	-	លោកវរៈសេនីយ៍ត្រី	ចាន់	សុខា	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
១៣	-	លោកវរៈសេនីយ៍ត្រី	ជា	វ៉ារុធ	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
១៤	-	លោកវរៈសេនីយ៍ត្រី	អ៊ុម	ច័ន្ទពៅ	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
១៥	-	លោកវរៈសេនីយ៍ត្រី	ហុង	លីណូ	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
១៦	-	លោកវរៈសេនីយ៍ត្រី	កុប	តឹន	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
១៧	-	លោកអនុសេនីយ៍ឯក	ស៊ិន	សុផា	នាយផ្នែក នៃសេនាធិការដ្ឋាន
១៨	-	លោកអនុសេនីយ៍ឯក	ជា	ឡូយ	នាយផ្នែក នៃសេនាធិការដ្ឋាន
១៩	-	លោកអនុសេនីយ៍ឯក	ស៊ុំ	ថា	មេបញ្ជាការវរៈសេនាតូច នៃសេនាធិការដ្ឋាន

គ.<u>មេជាយសិទ្ធការខារ</u>

១	-	លោកវរៈសេនីយ៍ត្រី	សំ	ណែត	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
២	-	លោកវរៈសេនីយ៍ត្រី	ធុច	សុខជា	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
៣	-	លោកវរៈសេនីយ៍ត្រី	ខិន	សំបូរ	នាយរងការិយាល័យ នៃសេនាធិការដ្ឋាន
៤	-	លោកអនុសេនីយ៍ឯក	ចាន់	សារឿន	នាយផ្នែក នៃសេនាធិការដ្ឋាន
៥	-	លោកអនុសេនីយ៍ឯក	ឡឹក	វណ្ណី	នាយផ្នែក នៃសេនាធិការដ្ឋាន
៦	-	លោកអនុសេនីយ៍ឯក	ម៉ាក់	អ៊ុម	នាយផ្នែក នៃសេនាធិការដ្ឋាន
៧	-	លោកអនុសេនីយ៍ឯក	រស់	សារុធ	នាយផ្នែក នៃសេនាធិការដ្ឋាន
៨	-	លោកអនុសេនីយ៍ឯក	ងួន	ផេងសែ	នាយផ្នែក នៃសេនាធិការដ្ឋាន
៩	-	លោកអនុសេនីយ៍ឯក	ធន់	ស្មុក	នាយផ្នែក នៃសេនាធិការដ្ឋាន
១០	-	លោកអនុសេនីយ៍ឯក	ឥុជ	ដានី	នាយផ្នែក នៃសេនាធិការដ្ឋាន
១១	-	លោកអនុសេនីយ៍ឯក	តូច	សុតន្ធា	នាយផ្នែក នៃសេនាធិការដ្ឋាន
១២	-	លោកអនុសេនីយ៍ឯក	អឹង	កុមារ	នាយផ្នែក នៃសេនាធិការដ្ឋាន
១៣	-	លោកអនុសេនីយ៍ឯក	ហេង	អាន	នាយផ្នែក នៃសេនាធិការដ្ឋាន
១៤	-	លោកអនុសេនីយ៍ឯក	អ៊ុយ	រើត	នាយផ្នែក នៃសេនាធិការដ្ឋាន
១៥	-	លោកអនុសេនីយ៍ឯក	កោសារី	វឌ្ឍនា	មន្ត្រី នៃសេនាធិការដ្ឋាន

១៦	-	លោកអនុសេនីយ៍ទោ	កុយ	ចក់	នាយរងផ្នែក នៃសេនាធិការដ្ឋាន
១៧	-	លោកអនុសេនីយ៍ទោ	ឆេង	សុង	នាយរងផ្នែក នៃសេនាធិការដ្ឋាន
១៨	-	លោកអនុសេនីយ៍ទោ	ញ៉ឹក	ចំរើន	នាយរងផ្នែក នៃសេនាធិការដ្ឋាន
១៩	-	លោកអនុសេនីយ៍ទោ	គួយ	សេងហ៊ើ	នាយរងផ្នែក នៃសេនាធិការដ្ឋាន
២០	-	លោកអនុសេនីយ៍ទោ	អ៊ុង	សុភី	នាយរងផ្នែក នៃសេនាធិការដ្ឋាន
២១	-	លោកអនុសេនីយ៍ទោ	រ៉ែម	សុផាន់	មេបញ្ជាការរងវរៈសេនាតូច នៃសេនាធិការដ្ឋាន
២២	-	លោកអនុសេនីយ៍ទោ	អ៊ី	វណ្ណា	មេបញ្ជាការរងវរៈសេនាតូច នៃសេនាធិការដ្ឋាន
២៣	-	លោកអនុសេនីយ៍ទោ	អ៊ូ	ផល្លា	មេបញ្ជាការរងវរៈសេនាតូច នៃសេនាធិការដ្ឋាន
២៤	-	លោកអនុសេនីយ៍ទោ	ខៀវ	វិចិត្រ	មន្ត្រី នៃសេនាធិការដ្ឋាន
២៥	-	លោកអនុសេនីយ៍ត្រី	នាក់	ចន្ថា	មេបញ្ជាការកងវរៈសេនាធំ នៃសេនាធិការដ្ឋាន
២៦	-	លោកអនុសេនីយ៍ត្រី	ងួន	ប៊ុនធន	មេបញ្ជាការកងវរៈសេនាធំ នៃសេនាធិការដ្ឋាន
២៧	-	លោកអនុសេនីយ៍ត្រី	ផាន់	សំអេន	មេបញ្ជាការកងវរៈសេនាធំ នៃសេនាធិការដ្ឋាន
២៨	-	លោកអនុសេនីយ៍ត្រី	រ៉ែម	ផា	មន្ត្រី នៃសេនាធិការដ្ឋាន
២៩	-	លោកព្រិន្ទបាលឯក	នុត	ផល្លា	មេបញ្ជាការរងកងវរៈសេនាតូច នៃសេនាធិការដ្ឋាន
៣០	-	លោកព្រិន្ទបាលឯក	សំ	សំអាត	មេបញ្ជាការរងកងវរៈសេនាតូច នៃសេនាធិការដ្ឋាន
៣១	-	លោកព្រិន្ទបាលទោ	សួង	សុរិយា	មន្ត្រី នៃសេនាធិការដ្ឋាន

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងសហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ សីហា ឆ្នាំ២០០៥

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៦៧៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើតនិងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសការងារ** ជូនជាកិច្ចបច្ឆាមរណៈ ចំពោះសពមន្ត្រី ០២រូប ដែលបានធ្វើមរណកាល កន្លងទៅ ដូចមានរាយនាមខាងក្រោម :-

១-សពលោក **សុខ សេងហុង** អតីតប្រធាននាយកដ្ឋានរបបគណនេយ្យ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

២-សពលោក **អយ គីមឈាង** អនុប្រធាននាយកដ្ឋានវិនិយោគ និងសហប្រតិបត្តិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៦ ខែ ៧ ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា ១ និង មាត្រា ២
-រាជកិច្ច
SR 127 -ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៧ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តបាត់ដំបង

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនឯកឧត្តម អស់លោក ចំនួន១០រូប ដែលមានស្នាដៃល្អ និង គុណបំណាច់ខ្ពស់ ក្នុងការកសាងហេដ្ឋារចនាសម្ព័ន្ធលើគ្រប់វិស័យ រួមចំណែកក្នុងការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ នៅក្នុងស្រុកបវេល ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ :-

ក_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-ឯកឧត្តម **គង ចំន្ទ** សមាជិកព្រឹទ្ធសភា

២-ឯកឧត្តម **ជួង ខ្វា** ទីប្រឹក្សា ឯកឧត្តម ស ខេង និង ប្រធានមន្ទីរសាធារណការនិងដឹកជញ្ជូនខេត្ត

ខ_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១-លោក **ឈេង ទី** អគ្គនាយករងរដ្ឋបាលក្រសួងមហាផ្ទៃ

២-លោក **ស្រី សៀង** ប្រធានសាខាគយ និងរដ្ឋាករ

គ_មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សរិទ្ធិ :

១-លោក **ចៅ ចណ្ណលី** ទីប្រឹក្សាក្រសួងមហាផ្ទៃ

២-លោក **ព្រាំ សុផាន** អភិបាលស្រុកបវេល

៣-លោក **ម៉ៅ ផល្លា** ប្រធានមន្ទីរប្រៃសណីយ៍និងទូរគមនាគមន៍ខេត្ត

៤-លោក **ឃួយ គីមឡុង** ប្រធាននាយកដ្ឋានរដ្ឋបាលទូទៅក្រសួងមហាផ្ទៃ

៥-លោក **ម៉ែន ម៉ុនរិទ្ធិ** អនុប្រធានទី១ នាយកដ្ឋានកិច្ចការរដ្ឋបាល អគ្គលេខាធិការដ្ឋានក្រសួងមហាផ្ទៃ

៦-លោក **ឈឹម មង្គល** ជំនួយការ ឯកឧត្តម ស ខេង ឧបនាយករដ្ឋមន្ត្រី

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។/៕

រាជធានីភ្នំពេញ, ថ្ងៃទី ១១ ខែ [illegible] ឆ្នាំ ២០០៥

ហ៊ុន សែន

<u>កន្លែងទទួល</u> :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

Ps-143

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៧៣៤ អនក្រ.ធក

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការ តែងតាំង រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ អភិបាលខេត្តបាត់ដំបង

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនអស់លោក លោកស្រី ចំនួន៧៦រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចបំរើជាតិមាតុភូមិ នៅក្នុងស្រុកបវេល ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ :-

ក.មេដាយមាសការងារ :

១-លោក	**ឈឹម នី**	អនុប្រធានទី១ នាយកដ្ឋានពន្ធនាគារ ក្រសួងមហាផ្ទៃ
២-លោក	**ឌី សុខផាន**	អនុប្រធាននាយកដ្ឋានកិច្ចការនយោបាយ ក្រសួងមហាផ្ទៃ
៣-លោក	**អៀម ចយ**	អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ
៤-លោក	**កែវ សែន**	អភិបាលស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ
៥-លោក	**ម៉ៃ យូរំណាល**	ជំនួយការឯកឧត្តម ស ខេង សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ
៦-លោកវរសេនីយ៍ឯក	**ឡុច សារ៉ែន**	មេបញ្ជាការរង កងពលតូចលេខ ៥៣
៧-លោកវរសេនីយ៍ទោ	**ជុំ សំណាង**	ប្រធានលេខាធិការដ្ឋាន នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយរដ្ឋបាល និង នគរបាល ក្រសួងមហាផ្ទៃ
៨-លោកវរសេនីយ៍ទោ	**ពុំ ចាន់**	ស្នងការរងនគរបាល ខេត្តបាត់ដំបង

៩-លោកវរសេនីយ៍ត្រី ជួន ផល្លា នាយរងការិយាល័យអគ្គលេខាធិការដ្ឋាន ក្រសួងមហាផ្ទៃ

១០-លោកវរសេនីយ៍ត្រី ខួន ស្រេង នាយរងការិយាល័យសាលាភូមិន្ទ នគរបាលជាតិ

១១-លោកវរសេនីយ៍ត្រី ស្រី សុខុន មេបញ្ជាការវរសេនាតូចការពារព្រំដែន លេខ ៨១៧

១២-លោកអនុសេនីយ៍ឯក ឡាយ ខុន មេបញ្ជាការរងវរសេនាតូចការពារព្រំដែន លេខ ៨១៧

១៣-លោកអនុសេនីយ៍ឯក ប្រាក់ សាយ មេបញ្ជាការរងវរសេនាតូចការពារព្រំដែន លេខ ៨១៧

១៤-លោកអនុសេនីយ៍ឯក ឃុង ឈី នាយកដ្ឋានបច្ចេកទេសព្រំដែន ក្រសួងមហាផ្ទៃ

១៥-លោក ឃួន ម៉ារុន ជំនួយការឯកឧត្តមអគ្គនាយករដ្ឋបាល ក្រសួងមហាផ្ទៃ

១៦-លោក អែល នី អនុប្រធានសាខាគយ និងរដ្ឋាករខេត្ត

១៧-លោក សែម ដារិទ្ធ អភិបាលរងស្រុកបវេល

១៨-លោក សូ សេង អធិការរង នៃក្រុមអធិការកិច្ចសាលាខេត្ត

១៩-លោក នាយ សុវមង្គ អនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត

២០-លោក គី ទរិទ្ធ អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត

២១-លោក ឆាំង ឈុនលីម អនុប្រធានមន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត

២២-លោក ឈុត គឿន មន្ទីរសាធារណការ និងដឹកជញ្ជូនខេត្ត

២៣-លោក ម៉ី ម៉ុនហួរ អនុប្រធានមន្ទីរប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត

២៤-លោក ភេង សារ៉េន ប្រធានពន្ធនាគារខេត្ត

២៥-លោកអនុសេនីយ៍ឯក សូ សែម អនុប្រធានការិ. ចរាចរផ្លូវគោកនៃស្នងការដ្ឋាននគរបាលខេត្ត

២៦-លោកស្រី ស៊ឹម សុខុន មន្ទីរអប់រំយុវជន និងកីឡាខេត្តបាត់ដំបង

ខ-មេដាយប្រាក់ការងារ :

១-លោកអនុសេនីយ៍ឯក អ៊ូ ឡឿង អធិការនគរបាលស្រុកបវេល

២-លោកអនុសេនីយ៍ឯក មោក ស៊ុន មេបញ្ជាការផ្នែកសឹករងស្រុកបវេល

៣-លោកស្រី រស់ សុគន្ធា ប្រធានការិយាល័យកិច្ចការនារី និងអតីតយុទ្ធជនស្រុក

៤-លោក រិន រ៉ែម ប្រធានការិ.សង្គមកិច្ចការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទាស្រុក

៥-លោក ឡុង ផន ប្រធានការិយាល័យកសិកម្ម រុក្ខាប្រមាញ់ស្រុក

៦-លោក ឈន គីមឡុង ប្រធានការិយាល័យភូមិបាលស្រុក

៧-លោក នូ ម៉ុនយ៉ាង ប្រធានការិយាល័យអភិវឌ្ឍន៍ជនបទស្រុក

៨-លោក ទិន ហួត ប្រធានការិយាល័យសេដ្ឋកិច្ចសាលាស្រុក

៩-លោកអនុសេនីយ៍ឯក ឆាំលំ ពៅ មេបញ្ជាការកងរាជអាវុធហត្ថស្រុក

១០-លោកអនុសេនីយ៍ឯក នួម ឆៃរួម អនុប្រធានការិ.បំភ័ន្តអក្សរៈនៃស្នងការដ្ឋាននគរបាលខេត្ត

១១-លោក អ៊ុង ម៉ុនហៃល ប្រធានការិយាល័យអប់រំយុវជន និងកីឡាស្រុក

១២-លោក ស៊ឹម ស៊ីន នាយកវិទ្យាល័យបវេល

១៣-លោក សរ សារី បុគ្គលិកមណ្ឌលសុខភាពស្រុកបវេល

១៤-លោក	ឃៀម ចាន់ឌី	អនុប្រធានការិយាល័យ កសិកម្ម រុក្ខាប្រមាញ់ស្រុក
១៥-លោក	ឈឿន ឡូត	មន្ត្រីការិយាល័យកិច្ចការនារី និង អតីតយុទ្ធជនស្រុក
១៦-លោក	ឃើន សារី	មន្ត្រីការិយាល័យភូមិបាលស្រុក
១៧-លោក	ពោ រឿញ	មន្ត្រីការិយាល័យធនធានទឹក និង ឧតុនិយមស្រុក
១៨-លោក	ឆាប់ ម៉ូរ៉ា	អនុប្រធានការិយាល័យសង្គមកិច្ច សាលាស្រុក
១៩-លោក	ឡឿន ឡុទ្ធី	ប្រធានការិយាល័យ ប្រៃសណីយ៍ស្រុក
២០-លោកស្រី	សែម ពៅ	មន្ត្រីការិយាល័យកិច្ចការនារី និងអតីតយុទ្ធជនស្រុក
២១-លោក	ព្រឹម សាលី	អនុប្រធានស្នាក់ការពន្ធដារ ស្រុក
២២-លោក	ស៊ិន ឆ៊ាន់	មន្ត្រីស្នាក់ការពន្ធដារ ស្រុក
២៣-លោក	ជេត សំអុល	ប្រធានស្នាក់ការពន្ធដារស្រុក
២៤-លោក	គល សែន	អនុប្រធានការិយាល័យកិច្ចការនារីនិងអតីតយុទ្ធជនស្រុក
២៥-លោក	នួន គឹមសុខ	មន្ត្រីប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត
២៦-លោក	សុខ សារ៉ូ	មន្ត្រីប្រៃសណីយ៍ និងទូរគមនាគមន៍ខេត្ត
២៧-លោក	យន់ យូរ	ប្រធានការិយាល័យរដ្ឋបាលទូទៅសាលាស្រុក
២៨-លោក	ជួល សារ៉ែត	មន្ត្រីការិយាល័យហិរញ្ញវត្ថុស្រុក
២៩-លោក	យន់ រិន	ប្រធានការិយាល័យបរិស្ថានស្រុក
៣០-លោកស្រី	ទីន វណ្ណា	អនុប្រធានការិយាល័យសង្គមកិច្ចស្រុក
៣១-លោក	នូ នរីវណ្ណ	មន្ត្រីមន្ទីរសាធារណការ និង ដឹកជញ្ជូនខេត្ត
៣២-លោក	គឹម ចិន្តា	ប្រធានការិយាល័យសាធារណការនិងដឹកជញ្ជូនស្រុក
៣៣-លោកអនុសេនីយ៍ទោ	អ៊ុន ម៉ុន្ថា	មេបញ្ជាការរងកងរាជអាវុធហត្ថស្រុក
៣៤-លោកអនុសេនីយ៍ទោ	អ៊ិម អខ្សា	ប្រធានផ្នែកល្បាតត្រួតពិនិត្យចល័តនៃស្នងការដ្ឋាននគរបាលខេត្ត
៣៥-លោកអនុសេនីយ៍ទោ	ឡេង វណ្ណា	មេបញ្ជាការរងកងរាជអាវុធហត្ថស្រុក
៣៦-លោកអនុសេនីយ៍ទោ	ឃៀម ម៉ុនឈឿប	អធិការរងនគរបាលស្រុក
៣៧-លោកអនុសេនីយ៍ទោ	សួស ឈាង	អធិការរងនគរបាលស្រុក
៣៨-លោកអនុសេនីយ៍ទោ	ឃួន រិទ្ធិ	អធិការរងនគរបាលស្រុក
៣៩-លោកអនុសេនីយ៍ទោ	នែម ម៉ុយ	មេបញ្ជាការរងសឹករងស្រុក
៤០-លោក	អឿន ខ្សុល	មន្ត្រីស្នាក់ការពន្ធដារស្រុក
៤១-លោក	ខៀវ សំអន់	មន្ត្រីភូមិបាលស្រុក
៤២-លោក	អ៊ុន ឆាន	ស្មៀនសាលាស្រុក
៤៣-លោក	សុខ សិ	មន្ត្រីសាធារណការ និងដឹកជញ្ជូនខេត្ត
៤៤-លោក	ឈឿន ចំរើន	មន្ត្រីសាធារណការ និងដឹកជញ្ជូនខេត្ត
៤៥-លោកស្រី	គឹម សុគន្ធារី	មន្ត្រីសាធារណការ និងដឹកជញ្ជូនខេត្ត

៤៦-លោក	ដេង ហ៊ាំ	មន្ត្រីសាធារណការ និងដឹកជញ្ជូនខេត្ត
៤៧-លោក	អេង ឈាង	មន្ត្រីសាធារណការ និងដឹកជញ្ជូនខេត្ត
៤៨-លោក	អ៊ុង ប៊ីហាច់	មន្ត្រីសាធារណការ និងដឹកជញ្ជូនខេត្ត
៤៩-លោក	នូ ផល្លា	មន្ត្រីសាធារណការ និងដឹកជញ្ជូនខេត្ត
៥០-លោក	សក់ សំពាន់	មន្ត្រីសាធារណការ និងដឹកជញ្ជូនខេត្ត

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងអភិបាលខេត្តបាត់ដំបង ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

<u>កន្លែងទទួល</u> :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-អគ្គលេខាធិការរាជរដ្ឋាភិបាល
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចមាត្រា ១ និង មាត្រា ២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

Ps-145

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៧៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពី

ការដាក់អោយមន្ត្រីរាជការចូលនិវត្តន៍

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី ១៣ ខែ កក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែមសំដៅធានានូវដំណើរការជាប្រក្រតី នៃស្ថាប័នជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ ជស/រកត/០២០០/១០៤ ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០០០ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីរដ្ឋបាលជាន់ខ្ពស់ ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ៨០ អនក្រ.បក ចុះថ្ងៃទី ០៦ ខែសីហា ឆ្នាំ ២០០២ ស្តីពីការគ្រប់គ្រងដំណើរការ នៃការដាក់មន្ត្រីរាជការស៊ីវិល អោយចូលនិវត្តន៍តាមអាយុ តាមប្រព័ន្ធពត៌មានវិទ្យា
- យោងតាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សម្រេច

មាត្រា ១ : ត្រូវបានដាក់អោយលោក **នុច ខាំស៊ឿន** អនុមន្ត្រីថ្នាក់លេខ ៦ អភិបាលស្រុកតាវែង ខេត្តរតនគីរី ចូលនិវត្តន៍ ។

មាត្រា ២ : បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

មាត្រា ៣ : រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័ន ដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ . ថ្ងៃទី ១៥ ខែ [illegible] ឆ្នាំ ២០០៥

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

__កន្លែងទទួល :__

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ១ និងមាត្រា ៣*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ...៧២៦...អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយមុនីសារាភ័ណ្ឌ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី០៥ ខែ តុលា ឆ្នាំ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសុខាភិបាល

សម្រេច

មាត្រា១: ត្រូវបានបំពាក់ **មេដាយមុនីសារាភ័ណ្ឌ** តាមលំដាប់ថ្នាក់ ជូនឯកឧត្តម លោកសាស្ត្រាចារ្យមហាបរិញ្ញា ចំនួន១៤រូប ដែលបានជួយបណ្តុះបណ្តាល អភិវឌ្ឍន៍ធនធានមនុស្ស លើវិស័យសុខាភិបាល និងរួមចំណែកស្ថាបនា សាកលវិទ្យាល័យ វិទ្យាសាស្ត្រសុខាភិបាល ដូចមានរាយនាមខាងក្រោម :-

ក.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ ធិបឌិន្ទ :

១-លោកសាស្ត្រាចារ្យមហាបរិញ្ញា **ម៉ី សាមេឌី** អគ្គលេខាធិការកាកបាទក្រហមកម្ពុជា អតីតព្រឹទ្ធបុរស មហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និង ទន្តសាស្ត្រ ។

២-លោកសាស្ត្រាចារ្យមហាបរិញ្ញា **ឌូ គីមឆោះ** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល អតីតសាកលវិទ្យាធិការ សាកលវិទ្យាល័យវិទ្យាសាស្ត្រសុខាភិបាល ។

៣-លោកសាស្ត្រាចារ្យមហាបរិញ្ញា **លី ម៉ូរ** ប្រធានគណៈគ្រូពេទ្យកម្ពុជា អតីតព្រឹទ្ធបុរសមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និង ទន្តសាស្ត្រ ។

៤-លោកសាស្ត្រាចារ្យមហាបរិញ្ញា **សៅ សុគន្ធន** អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល និងជាប្រធានគណៈកម្មការ នាយកនៃ សមាគមគ្រូពេទ្យកម្ពុជា ។

ខ.មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ សេនា :

១-លោកសាស្ត្រាចារ្យមហាបរិញ្ញា **ជា ឆាយ** អនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល និងជាប្រធានក្រុមប្រឹក្សាភិបាល ។

២-លោកសាស្ត្រាចារ្យមហាបរិញ្ញា **សេង លឹមនៅ** រដ្ឋលេខាធិការ ទីស្តីការគណៈរដ្ឋមន្ត្រី អតីតព្រឹទ្ធបុរសរងមហាវិទ្យាល័យវេជ្ជសាស្ត្រ ឱសថសាស្ត្រ និង ទន្តសាស្ត្រ និងជាសមាជិកក្រុមប្រឹក្សាភិបាល ។

៣-ឯកឧត្តម **ម៉ិន ស៊ុខ** រដ្ឋលេខាធិការ ក្រសួងអប់រំយុវជន និងកីឡា និងជាសមាជិកក្រុមប្រឹក្សាភិបាល ។

៤-លោកសាស្ត្រាចារ្យមហាបរិញ្ញា **អេង ហួត** រដ្ឋលេខាធិការ ក្រសួងសុខាភិបាល និងជាសមាជិកក្រុមប្រឹក្សាភិបាល ។

គ-មេដាយមុនីសារាភ័ណ្ឌ ថ្នាក់ អស្សឫទ្ធិ :

១-លោកសាស្ត្រាចារ្យមហាបរិញ្ញា **អ៊ុំ សុផល** សាកលវិទ្យាធិការ និងជាសមាជិកក្រុមប្រឹក្សាភិបាល

២-លោកសាស្ត្រាចារ្យមហាបរិញ្ញា **យក់ ស៊ូផាន់ណា** សាកលវិទ្យាធិការរង និងជាសមាជិកក្រុមប្រឹក្សាភិបាល ។

៣-លោក **នូច ឡេង** ប្រធាននាយកដ្ឋានហិរញ្ញកិច្ច ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងជាសមាជិកក្រុមប្រឹក្សាភិបាល ។

៤-លោកសាស្ត្រាចារ្យមហាបរិញ្ញា **ឡឹក សាន់ឌី** អតីតប្រធានមជ្ឈមណ្ឌលជាតិកំចាត់ជំងឺគ្រុនចាញ់ ។

៥-លោកសាស្ត្រាចារ្យមហាបរិញ្ញា **គង់ គឹមសាន** អតីតប្រធានអសនវេជ្ជសាស្ត្រ

៦-លោកសាស្ត្រាចារ្យមហាបរិញ្ញា **ទើង ថៃ** ប្រធានមន្ទីរសុខាភិបាលរាជធានីភ្នំពេញ និងជាប្រធានអសនសិរីវិទ្យា និងសរីរោគវិទ្យា ។

មាត្រា២: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រីក្រសួងសុខាភិបាល ត្រូវអនុវត្តអនុក្រឹត្យនេះអោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥

ហ៊ុន សែន

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១ និង មាត្រា ២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

B.Tha.43

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៦៧៧ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការលុបឈ្មោះមន្ត្រីរាជការក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/0៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ២៦ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៤ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ

សម្រេច

មាត្រា១. ត្រូវបានលុបឈ្មោះ លោក **ឡាំ សារ៉ាវុធ** អគ្គនាយករងបច្ចេកទេសវប្បធម៌ ដែលទទួលមរណៈភាព ចេញពីក្របខ័ណ្ឌមន្ត្រីរាជការនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ចាប់ពីខែ មេសា ឆ្នាំ ២០០៥ តទៅ។

មាត្រា២. បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះត្រូវចាត់ទុកជានិរាករណ៍។

មាត្រា៣. រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ដូចមាត្រា ៣
- ឯកសារ-កាលប្បវត្តិ ✓

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ៦៣៨ អនក្រ.បក

អនុក្រឹត្យ
ស្តីពី
ការបន្ថែមសមាសភាព នៃគណៈកម្មការបណ្ឌិតសភា
ទទួលបន្ទុកអនុម័តពាក្យច្បាប់

** * **

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥៨ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីការបង្កើតក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌
- បានឃើញអនុក្រឹត្យលេខ៣៦ អនក្រ.បក ចុះថ្ងៃទី ១៤ ខែ ឧសភា ឆ្នាំ ២០០៣ ស្តីពីការបង្កើតគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់
- យោងតាមការចាំបាច់នៃការងារ

ស ម្រេ ច

មាត្រា ១ : ត្រូវបានបន្ថែមសមាសភាព :

១- ឯកឧត្តម **ណាឌី តាន់** ជាទីប្រឹក្សា នៃគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ។

២- ឯកឧត្តម **ស្វ មុយឃៀង** ជាសមាជិក នៃគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រធានគណៈកម្មការបណ្ឌិតសភាទទួលបន្ទុកអនុម័តពាក្យច្បាប់ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០០៥

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច និងឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខៈ ៧៣៧ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតម្លើងឋានន្តរស័ក្តិមន្ត្រីរាជការ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

